# ព្រះរាជក្រម នស/រកម/០១៩៦/១៧

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

## ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

## ប្រកាសអោយប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន ដែលរដ្ឋសភាបានអនុម័តនាសម័យ ប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពី

## ការបង្កើតក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន

**មាត្រា ១ :** ត្រូវបានបង្កើតក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២ :** ក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យសង្គមកិច្ច វិស័យការងារនិងវិស័យអតីតយុទ្ធជន នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ :** ក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ឬរដ្ឋលេខាធិការមួយរូប ដែលអាចអមដោយអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

**មាត្រា ៤ :** ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥ :** បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :** ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

* * *